4.3-ធនធានសេដ្ឋកិច្ច-សង្គម

គំរោងបូមខ្សាច់ដើម្បីបង្កើតឃ្លងនាវាចេញ-ចូល និងចាក់ខ្សាច់បំពេញតំបន់សេដ្ឋកិច្ចពិសេស គឺជាគំរោងមួយរបស់ក្រុមហ៊ុនKAMPOT PORT Co., Ltd ធ្វើការអភិវឌ្ឍន៍កំពង់ផែកំពត និងតំបន់សេដ្ឋកិច្ចពិសេស ដែលស្ថិតនៅក្នុងភូមិគីឡូ12 ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ដោយមានក្តីសង្ឃឹមថា នឹងធ្វើឲ្យចរន្តសេដ្ឋកិច្ចនៅក្នុងតំបន់នេះមានការរីកចំរើនឲ្យបានប្រសើរឡើង ព្រមជាមួយនិងការទាក់ទាញវិនិយោគិនក្នុងស្រុក និងវិនិយោគិនបរទេសមកបណ្តាក់ទុននៅក្នុងប្រទេសកម្ពុជា។

4.3.1-គោលបំណងនៃការសិក្សាធនធានសេដ្ឋកិច្ច-សង្គម

គោលបំណងនៃការសិក្សានូវធនធានសេដ្ឋកិច្ច-សង្គម មុនពេលវត្តមានគំរោងកើតមានឡើង គឺដើម្បីយល់ដឹងពីស្ថានភាព និងសក្តានុពលនៃសេដ្ឋកិច្ច-សង្គមរបស់ប្រជាពលរដ្ឋក្នុង និងក្បែរតំបន់គំរោង ដែលក្នុងនោះការសិក្សាផ្តោតលើឃុំចំនួន3៖ (1)-ឃុំបឹងទូក (2)-ឃុំកោះតូច និង (3)-ឃុំព្រែកស្នោត ស្រុកទឹកឈូ ខេត្តកំពត ជាឃុំដែលមានការពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គំរោង។

ដូចនេះ គោលបំណងនៃការសិក្សាទៅលើធនធានសេដ្ឋកិច្ច-សង្គមរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោង គឺក្រុមការងារCES ផ្តោតទៅលើ៖

-ការសិក្សាពីប្រជាសាស្ត្រ និងការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ៖ ចំនួនគ្រួសារ ចំនួនមនុស្សសរុប
-ស្ថានភាពសេដ្ឋកិច្ច៖ មុខរបរ និងប្រាក់ចំណូល (ប្រភពចំណូលសំខាន់ និងបន្ទាប់បន្សំ)
-ការប្រើប្រាស់ដី
-ការប្រើប្រាស់ទឹក
-ការប្រើប្រាស់ថាមពល
-ការអប់រំ
-សុខភាពសាធារណៈ
-ហេដ្ឋារចនាសម្ព័ន្ធក្បែរតំបន់គំរោង
-ប្រពៃណី/ទំនៀមទំលាប់ និងជនជាតិ
-តំបន់ទេសចរណ៍
-សហគមន៍នេសាទ និង សហគមន៍ការពារស្មៅសមុទ្រ។

4.3.2-វិធីសាស្ត្រអង្កេត និងការកំណត់ចំនួនសំណាក

ក្នុងអំឡុងពេលនៃការចុះសិក្សារបស់ក្រុមការងារCES ទៅលើធនធានសេដ្ឋកិច្ច-សង្គមដែលបានប្រព្រឹត្ត ទៅចាប់ពីថ្ងៃទី27 ខែកុម្ភៈ ដល់ថ្ងៃទី03 ខែមីនា ឆ្នាំ 2010 លើឃុំចំនួនបីដែលមានការពាក់ព័ន្ធទៅនឹង សកម្មភាពគំរោង ដើម្បីធ្វើការអង្កេតទៅលើប្រជាពលរដ្ឋដែលក្នុងនោះក្រុមការងារបានជ្រើសរើសភូមិគោលដៅមកធ្វើការសម្ភាសន៍រួមមាន

(1)-ឃុំបឹងទូក ៖ មានចំនួន01ភូមិ គឺភូមិឈូស
(2)-ឃុំកោះតូច ៖ មានចំនួន04ភូមិ គឺភូមិគីឡូ12 ភូមិព្រែកចេក ភូមិកណ្តាល និងភូមិព្រែកអំពិល
(3)-ឃុំព្រែកស្នោត ៖ មានចំនួន04ភូមិ គឺភូមិត្រពាំងរពៅ ភូមិព្រែកក្រែង ភូមិព្រែកស្នោត និងភូមិចង្ហោន

ក-វិធីសាស្ត្រអង្កេត

វិធីសាស្ត្រដែលក្រុមសិក្សាយើងខ្ញុំធ្វើការសិក្សាអង្កេតអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមនៅក្បែរតំបន់គំរោង គឺប្រមូលទិន្នន័យដែលមានស្រាប់(Secondary Data)ពីភូមិ-ឃុំ និងទិន្នន័យចំបង(Primary Data)តាមរយៈ ធ្វើការសម្ភាសន៍ផ្ទាល់ជាមួយប្រធានភូមិ មេឃុំ ឬជំទប់ឃុំ និងប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់គំរោង ដោយប្រើប្រាស់កម្រងសំនួរដែលបានរៀបចំហើយជាស្រេចទៅតាមលក្ខខណ្ឌដែលក្រុមការងារ ត្រូវការយកមកធ្វើការសិក្សា។

-ទិន្នន័យដែលមានស្រាប់៖ គឺជាឯកសារ ឬរបាយការណ៍ដែលបានបោះពុម្ពផ្សាយចុងក្រោយ និងមានការពាក់ព័ន្ធនឹងស្ថានភាពភូមិ-ឃុំក្បែរតំបន់គំរោង។

-ទិន្នន័យចំបង៖ គឺបានមកពីការសម្ភាសន៍ផ្ទាល់ជាមួយប្រធានភូមិ-ឃុំ និងប្រជាពលរដ្ឋដែល រស់នៅក្នុងតំបន់គំរោង (តារាង 4.22)។

តារាង 4.22 ព័ត៌មានទិន្នន័យភូមិ-ឃុំ

ស្រុក	ឃុំ	ភូមិ	ចំនួនគ្រួសារ
ស្រុកទឹកឈូ	បឹងទូក= 1,040	ឈូស	314
		កែបថ្មី	414
		ទទឹងថ្ងៃ	312
	កោះតូច= 1,284	គីឡូ12	544
		ព្រៃកចេក	143
		កណ្តាល	197
		ព្រៃកអំពិល	400
	ព្រៃកស្នោត= 1,704	ត្រពាំងរពៅ	731
		ព្រៃកក្រែង	314
		ព្រៃកស្នោត	300
		ចង្ហោន	359

(ប្រភព: ការសម្ភាសន៍ផ្ទាល់ជាមួយប្រធានភូមិ-ឃុំ នៅខែមីនា ឆ្នាំ2010)

យោងទៅលើផែនទីកំណត់ទីតាំងរបស់គំរោង (រូបភាព 3.2) ក្រុមសិក្សាបានកំណត់ឃើញថាមានភូមិ ចំនួន2 ដែលនៅក្នុងឃុំបឹងទូកគឺស្ថិតនៅក្រៅតំបន់គំរោង(ស្ថិតនៅឆ្ងាយពីតំបន់គំរោង)។ ដូច្នេះក្រុមសិក្សាយើងខ្ញុំ បានកំណត់យកភូមិចំនួន9 ក្នុងចំណោម11ភូមិ របស់ឃុំទាំង3 ដើម្បីធ្វើការអង្កេត។

ខ-ការកំណត់ចំនួនសំណាក (Sample)

ក្រុមសិក្សាបានបែងចែកជា2ផ្នែក ក្នុងការប្រមូលទិន្នន័យចំបងពីភូមិ-ឃុំ ដែលស្ថិតនៅក្បែរតំបន់គំរោងគឺ៖

1- ការប្រមូលទិន្នន័យតាមរយៈការប្រើប្រាស់កម្រងសំនួរ(ឧបសម្ព័ន្ធ 4.2) ដោយបានសម្ភាសន៍ផ្ទាល់ជាមួយអាជ្ញាធរភូមិ-ឃុំចំនួន12សំណាក ដែលស្ថិតនៅក្បែរតំបន់គំរោង(បញ្ជីឈ្មោះរបស់អាជ្ញាធរភូមិ-ឃុំ ដែលបានសម្ភាសន៍មានបង្ហាញជូនក្នុងឧបសម្ព័ន្ធ4.4)។
2- យោងទៅលើតារាង 4.22 ក្រុមសិក្សាបានគណនាឃើញថា ចំនួនគ្រួសារសរុបទាំងអស់ក្នុងភូមិពាក់ព័ន្ធទាំង9 គឺស្មើនឹង3297គ្រួសារ។ ចំនួននេះ គឺជាចំនួនដ៏ច្រើនលើសលប់ដែលក្រុមសិក្សាត្រូវការ ចំណាយ

ពេលវេលាដ៏យូរដើម្បីអង្កេតសិក្សា។ ដូច្នេះ ក្រុមសិក្សាយើងខ្ញុំបានសំរេចចិត្តកំណត់យក រូបមន្តសំរាប់ប្រើប្រាស់ក្នុងការគណនារកសំណាក ដែលមានកម្រិតជឿជាក់រហូតដល់90ភាគរយ (លំអៀងតែ10 ភាគរយ) ដែលវិធីសាស្ត្រនេះត្រូវបានគេប្រើភាគច្រើន ដើម្បីប្រមូលទិន្នន័យតាមរយៈ ការសម្ភាសន៍ជាមួយប្រជាពលរដ្ឋដោយប្រើប្រាស់កម្រងសំនួរ(ឧបសម្ព័ន្ធ 4.1) ហើយបញ្ជីឈ្មោះដែលធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋយុំទាំង3 មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ 4.3។

<u>រូបមន្ត៖</u>

1- $n = N/[1+N(e)^2]$

2- $n_i = (n * N_i)/N$

<u>កំណត់សំគាល់៖</u>

N = ចំនួនសរុបក្នុងតំបន់ (គ្រួសារ)

Ni = ចំនួនសរុបក្នុងអនុតំបន់

n = ចំនួនសំណាកនៃតំបន់

ni = ចំនួនសំណាកនៃអនុតំបន់

e = កំរិតលំអៀង 10 ភាគរយ (កំរិតនៃការជឿជាក់រហូតដល់ 90ភាគរយ)

<u>ប្រភព</u>៖ Taro Yamane, Elementary Sampling Theory (1967)

តារាង 4.23 ទិន្នន័យសំណាកដែលត្រូវបានជ្រើសរើសក្នុងតំបន់គោលដៅ

ឈ្មោះ យុំ/ភូមិ	គ្រួសារ N/N_i	សំណាក n/n_i	គ្រួសារ ស្ត្រី
យុំ បឹងទូក	1040	91.22807018	9
ភូមិ រលួស	314	27.54385965	9
ភូមិ កែបថ្មី**	414	36.31578947	
ភូមិ ទទឹងថ្ងៃ**	312	27.36842105	
យុំ កោះតូច	1284	92.77456647	39
ភូមិ គីឡូ12	544	39.30635838	15
ភូមិ ព្រែកចេក	143	10.33236994	4
ភូមិ កណ្តាល	197	14.23410405	6
ភូមិ ព្រែកអំពិល	400	28.9017341	14
យុំ ព្រែកគ្នោត	1704	94.45676275	23
ភូមិ ត្រពាំងរពៅ	731	40.5210643	6
ភូមិ ព្រែកក្រែង	314	17.40576497	2
ភូមិ ព្រែកគ្នោត	300	16.62971175	8
ភូមិ ចង្ហោន	359	19.90022173	7
សរុប	4028	278.4593994	71

ចំណាំ: ** ភូមិមិនពាក់ព័ន្ធនិងគំរោង 215

រូបភាព 4.73 ភូមិ និងសហគមន៍នៅក្បែរតំបន់គំរោង



ក្រោយពីបានគណនារកសំណាកនៅក្បែរតំបន់គំរោងរួចមក ក្រុមសិក្សាយើងខ្ញុំបានកំណត់ចំនួនដែលត្រូវចុះសំភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ គឺស្មើនឹង215នាក់ តំណាងឲ្យគ្រួសារចំនួន215គ្រួសារ ដែលក្នុងនោះមានស្ត្រីចំនួន71នាក់ផងដែរ។

ក្រោយពីបានកំណត់ចំនួនសំណាកក្បែរតំបន់គំរោងរួចហើយ ក្រុមសិក្សាយើងខ្ញុំបានចុះទៅពិនិត្យជាក់ស្តែងអំពីស្ថានភាពតាំងទីលំនៅរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោង គឺមានលក្ខណៈស្ថានភាពខុសៗគ្នាពុំច្បាស់លាស់ដូច្នេះយើងខ្ញុំក៏កំណត់វិធីសាស្ត្រជ្រើសរើសដោយចៃដន្យ ដោយកំណត់ក្នុងភូមិខ្លះជ្រើសរើសចំនួន5ផ្ទះចូលសម្ភាសន៍ម្តង។ ចំណែកភូមិខ្លះទៀត3ផ្ទះចូលសម្ភាសន៍ម្តង ធ្វើយ៉ាងណាឲ្យការជ្រើសរើសសំណាកដោយចៃដន្យ គ្របដណ្តប់ពេញផ្ទៃភូមិ-ឃុំក្បែរតំបន់គំរោង។

4.3.2-លទ្ធផលនៃការសិក្សា

ក. ប្រជាសាស្ត្រ

យោងតាមការសិក្សារបស់ក្រុមការងារ CES បានធ្វើការសិក្សាវាយតំលៃ និងកំណត់គោលដៅអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋស្របតាមទីតាំងដែលក្រុមហ៊ុន KAMPOT PORT CO., LTD បានស្នើគំរោង ដែលមានការពាក់ព័ន្ធទៅនឹងឃុំចំនួន3 (តារាង 4.25)៖

តារាង 4.24 ស្ថិតិប្រជាពលរដ្ឋឃុំបឹងទូក ឃុំកោះតូច និងឃុំព្រែកស្នោត

ល.រ	ឈ្មោះភូមិ	ចំនួនប្រជាពលរដ្ឋសរុប			មធ្យមភាគមនុស្ស ក្នុងមួយគ្រួសារ
		ចំនួនគ្រួសារ	ចំនួនមនុស្ស	ស្ត្រី	
1	**ឃុំបឹងឈូក**	1,040	5,387	2633	5.18
1.1	ភូមិរលួស	314	1,612	800	5.13
1.2	ភូមិកែបថ្មី	414	2,073	1000	5.00
1.3	ភូមិទទឹងថ្ងៃ	312	1,702	833	5.45
2	**ឃុំកោះតូច**	1,284	6,698	3501	5.22
2.1	ភូមិគីឡូ12	544	2,859	1576	5.26
2.2	ភូមិព្រែកចេក	143	814	445	5.69
2.3	ភូមិកណ្តាល	197	992	497	5.04
2.4	ភូមិព្រែកអំពិល	400	2,033	983	5.08
3	**ឃុំព្រែកស្នោត**	1,704	8,757	3357	5.14
3.1	ភូមិត្រពាំងរពៅ	731	3,688	864	5.05
3.2	ភូមិព្រែកក្រែង	314	1,668	849	5.31
3.3	ភូមិព្រែកស្នោត	300	1,583	759	5.28
3.4	ភូមិចង្ហោន	359	1,818	885	5.06

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយមេភូមិ-ឃុំ (ខែមីនា ឆ្នាំ 2010)

តាមការចុះសម្ភាសន៍របស់ក្រុមការងារយើងខ្ញុំទៅលើប្រជាពលរដ្ឋចំនួន 27នាក់ ក្នុងភូមិរលួស ឃុំបឹងទូក បានឲ្យដឹងថា ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍មានបុរសចំនួន18នាក់ គឺស្មើនឹង67% ស្ត្រី9នាក់ គឺស្មើនឹង33%។

ជាមួយគ្នានេះដែរ តាមការសម្ភាសន៍ជាមួយប្រជាពលរដ្ឋភូមិទាំង4 របស់ឃុំកោះតូចចំនួន94នាក់ បានឲ្យដឹងថា ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍មានបុរសចំនួន55នាក់ គឺស្មើនឹង58.51% និងស្ត្រី39នាក់ គឺស្មើនឹង 41.49%។

ចំណែកភូមិទាំង4 របស់ឃុំព្រែកត្នោតចំនួន 94នាក់ បានឲ្យដឹងថា ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ មានបុរសចំនួន71នាក់ គឺស្មើនឹង75.53% និងស្ត្រី23នាក់ គឺស្មើនឹង24.47% (តារាង 4.25)។

តារាង 4.25 ភាគរយនៃប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍

ឈ្មោះភូមិ	ចំនួនអ្នកផ្តល់សម្ភាសន៍			
	បុរស	ភាគរយ	ស្ត្រី	ភាគរយ
ឃុំបឹងទូក	18	67.00	9	33.00
1. ភូមិរលួស	18	67.00	9	33.00
ឃុំកោះតូច	55	58.51	39	41.49
1. ភូមិគីឡូ12	24	61.50	15	38.50
2. ភូមិព្រែកចេក	6	60.00	4	40.00
3. ភូមិកណ្តាល	8	57.10	6	42.90
4. ភូមិព្រែកអំពិល	17	54.80	14	45.20
ឃុំព្រែកត្នោត	71	75.53	23	24.47
1. ភូមិត្រពាំងរពៅ	35	85.40	6	14.60
2. ភូមិព្រែកក្រែង	15	88.20	2	11.80
3. ភូមិព្រែកត្នោត	8	50.00	8	50.00
4. ភូមិចង្ហោន	13	65.00	7	35.00
សរុប	143	66.82	71	33.18

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ (ខែមីនា ឆ្នាំ 2010)

នៅក្នុងកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋមានអាយុតិចបំផុតចាប់ពី19ឆ្នាំ ទៅដល់71ឆ្នាំ ដែលក្នុងនោះមានវ័យអាយុ40ឆ្នាំ មានចំនួនច្រើនជាងគេ គឺ13នាក់ ស្មើនឹង6% វ័យអាយុ35ឆ្នាំមានចំនួន12នាក់ គឺស្មើនឹង5.6% វ័យអាយុ45ឆ្នាំមានចំនួន11នាក់ គឺស្មើនឹង5.1% និងវ័យអាយុ30ឆ្នាំមានចំនួន10នាក់គឺស្មើនឹង4.7%។ ក្រៅពីវ័យអាយុដែលបានបញ្ជាក់ជូនខាងលើ ភាគច្រើនមានចំនួនតិចតួច ដូចមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ4.5។

ខ-មុខរបរ និងប្រាក់ចំណូល

ខ.1-មុខរបរ

ភូមិដែលនៅក្បែរទីតាំងគំរោងមានស្ថិតនៅជាប់នឹងសមុទ្រ ដែលប្រជាពលរដ្ឋមានមុខរបរចំបងជាការនេសាទ ប៉ុន្តែក៏មានមុខរបរផ្សេងទៀតផងដែរ។ តាមការសម្ភាសន៍ជាមួយប្រជាពលរដ្ឋទាំងបីឃុំបានឲ្យដឹងថា ពួកគាត់មានមុខរបរចំបងគឺ៖ អ្នកនេសាទមានចំនួន162នាក់ស្មើនឹង75.30% កសិករមានចំនួន23នាក់ស្មើនឹង10.70% មន្ត្រីរាជការមានចំនួន3នាក់ស្មើនឹង1.40% កម្មករមានចំនួន5នាក់ស្មើនឹង2.30% អ្នកលក់ដូរមាន3នាក់ស្មើនឹង1.40% និងប្រជាពលរដ្ឋដែលមានមុខរបរផ្សេងៗចំនួន19នាក់ស្មើនឹង8.80% (តារាង 4.26)។

តារាង 4.26 តារាងស្តីពីមុខរបរចំបងរបស់ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍

មុខរបរចំបង	ឃុំបឹងទូក		ឃុំកោះតូច		ឃុំព្រែកស្នោត		សរុប	
	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ
អ្នកនេសាទ	16	59.30	73	77.66	73	77.66	162	75.30
កសិករ	4	14.80	11	11.70	8	8.51	23	10.70
មន្ត្រីរាជការ	2	7.40	1	1.06	0	0	3	1.40
កម្មករ	1	3.70	1	1.06	3	3.19	5	2.30
អ្នកលក់ដូរ	1	3.70	0	0	2	2.13	3	1.40
ផ្សេងៗ	3	11.10	8	8.52	8	8.51	19	8.80
សរុប	27	100	94	100	94	100	215	100

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ (ខែមីនា ឆ្នាំ 2010)

តារាង 4.27 តារាងស្តីពីមុខរបរបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍

មុខរបរបន្ទាប់បន្សំ	ឃុំបឹងទូក		ឃុំកោះតូច		ឃុំព្រែកស្នោត		សរុប	
	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ
អ្នកនេសាទ	2	7.40	6	6.38	7	7.45	15	7.00
កសិករ	5	18.50	28	29.79	16	17.02	49	22.80
មន្ត្រីរាជការ	0	0	0	0	1	1.06	1	0.50
កម្មករ	1	3.70	6	6.38	2	2.13	9	4.20
អ្នកលក់ដូរ	0	0	3	3.19	2	2.13	5	2.30
ផ្សេងៗ	1	3.70	10	10.64	9	9.57	20	9.30
ពុំមានមុខរបរ	18	66.70	41	43.62	57	60.64	116	54.00
សរុប	27	100	94	100	94	100	215	100

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ (ខែមីនា ឆ្នាំ 2010)

កំណត់សំគាល់៖ ពុំមានមុខរបរមាននិយថាគ្មានមុខរបរបន្ទាប់បន្សំ

បន្ថែមពីលើនេះទៀត ការផ្តល់សម្ភាសន៍ជាមួយប្រជាពលរដ្ឋទាំងបីឃុំបានឲ្យដឹងដែរថា ពួកគាត់មានមុខរបរបន្ទាប់បន្សំគឺ៖ អ្នកនេសាទមានចំនួន15នាក់ស្មើនឹង7.00% កសិករមានចំនួន49នាក់ស្មើនឹង22.80% មន្ត្រីរាជការ មានចំនួន1នាក់ស្មើនឹង0.50% កម្មករមានចំនួន9នាក់ស្មើនឹង4.20% អ្នកលក់ដូរមាន5នាក់ស្មើនឹង2.305%។ ក្រៅពីមុខរបរធ្វើស្រែចំការ និងនេសាទ ប្រជាពលរដ្ឋនៅជាប់ទីតាំងគំរោងមានមុខរបរផ្សេងៗទៀតចំនួន20នាក់ស្មើនឹង9.30% ដូចជាការចិញ្ចឹមសត្ត លក់ដូរតិចតួច ដាំដំណាំ ដាំសារាយ អ្នកដឹកជញ្ជូន ជាងជួសជុល ព្រមទាំងប្រជាពលរដ្ឋ ដែលពុំមានមុខរបរបន្ទាប់បន្សំចំនួន116នាក់ ស្មើនឹង54.00% (តារាង 4.27)។

៨.2 ប្រាក់ចំណូល-ចំណាយរបស់ប្រជាពលរដ្ឋសំរាប់ឆ្នាំ2009

យោងតាមទិន្នន័យដែលដកស្រង់ចេញពី Statistical Yearbook 2008 នៃវិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងផែនការបានឲ្យដឹងថា ចំណូលផលិតផលសរុបក្នុងស្រុកសរុប (GDP) របស់ប្រជាពលរដ្ឋម្នាក់ៗក្នុងមួយឆ្នាំ គឺ USD 594 per capita ។

ដោយឡែក ឧបសម្ព័ន្ធ 4.6 បានបង្ហាញអំពីប្រាក់ចំណូល-ចំណាយប្រចាំគ្រួសារ និងចំនួនបំណុល ជាមធ្យមសម្រាប់ឆ្នាំ2009 របស់ប្រជាពលរដ្ឋភូមិទាំង9 ដែលក្រុមការងារ CESបានធ្វើការសម្ភាសន៍។ លទ្ធផលនៃការសម្ភាសន៍បានឲ្យដឹងថា៖

ឃុំបឹងទូក៖

-ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមគឺ2,715 USD សំរាប់មួយគ្រួសារ។ បើយោងតាមតារាង4.24 ដែលបង្ហាញអំពីចំនួនមនុស្សជាមធ្យមយ៉ាងតិច5នាក់ក្នុងមួយគ្រួសារ ដូចនេះ ចំណូលផលិតផលសរុបជាមធ្យម(GDP) របស់ប្រជាពលរដ្ឋម្នាក់ៗក្នុងមួយឆ្នាំគឺ USD 524

-ប្រាក់ចំណាយប្រចាំឆ្នាំជាមធ្យមគឺ 2,484 USD

-បំណុលប្រចាំឆ្នាំជាមធ្យមគឺ 15 USD ។

ឃុំកោះតូច៖

-ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមគឺ 3,221USD សំរាប់មួយគ្រួសារ។ បើយោងតាមតារាង4.24ដែលបង្ហាញអំពីចំនួនមនុស្សជាមធ្យមយ៉ាងតិច5នាក់ក្នុងមួយគ្រួសារ ដូចនេះ ចំណូលផលិតផលសរុបជាមធ្យម(GDP)របស់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំគឺ USD560

-ប្រាក់ចំណាយប្រចាំឆ្នាំជាមធ្យមគឺ 2,793USD

-បំណុលប្រចាំឆ្នាំជាមធ្យមគឺ 193USD។

ឃុំព្រែកត្នោត៖

-ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមគឺ2,739USDសំរាប់មួយគ្រួសារ។ បើយោងតាមតារាង4.24ដែលបង្ហាញអំពីចំនួនមនុស្សជាមធ្យមយ៉ាងតិច5នាក់ក្នុងមួយគ្រួសារ ដូចនេះ ចំណូលផលិតផលសរុបជាមធ្យម(GDP)របស់ប្រជាពលរដ្ឋម្នាក់ៗក្នុងមួយឆ្នាំគឺ USD 533

-ប្រាក់ចំណាយប្រចាំឆ្នាំជាមធ្យមគឺ 1,510 USD

-បំណុលប្រចាំឆ្នាំជាមធ្យមគឺ 499 USD។

☞ចំនួនថ្ងៃនៃការនេសាទនៅរដូវប្រាំង

យោងទៅតាមលទ្ធផលនៃការសម្ភាសន៍ជាមួយប្រជាពលរដ្ឋឃុំបឹងទូកចំនួន 59.30% ដែលជាអ្នកនេសាទបានឲ្យដឹងថា ប្រជាពលរដ្ឋដែលចេញទៅនេសាទនៅរដូវប្រាំង គឺចាប់ពីខែវិច្ឆិកា ដល់ខែមេសា ដែលក្នុងនោះមានប្រជាពលរដ្ឋចេញទៅនេសាទជាប្រចាំថ្ងៃមានចំនួន11.11% ចេញទៅនេសាទដែលមានរយៈពេលពី21-29ថ្ងៃ មានចំនួន

7.41% ហើយចេញទៅនេសាទតិចជាង20ថ្ងៃមានចំនួន18.52%។ ដោយឡែកប្រជាពលរដ្ឋមិនបានផ្តល់ចំលើយមានចំនួន62.96% ដូចបង្ហាញជូនក្នុងតារាង 4.29។

ចំណែក ប្រជាពលរដ្ឋឃុំកោះតូចវិញមានចំនួន77.66%ដែលជាអ្នកនេសាទបានឲ្យដឹងថា ប្រជាពលរដ្ឋដែលចេញទៅនេសាទនៅរដូវប្រាំង ដែលក្នុងនោះមានប្រជាពលរដ្ឋចេញទៅនេសាទជាប្រចាំថ្ងៃមានចំនួន19.15% ចេញទៅនេសាទដែលមានរយៈពេលពី21-29ថ្ងៃមានចំនួន21.28% ចេញទៅនេសាទតិចជាង20ថ្ងៃមានចំនួន41.49% ហើយប្រជាពលរដ្ឋមិនបានផ្តល់ចំលើយមានចំនួន18.08%។

ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋឃុំព្រែកស្នោតមានចំនួន77.66%ដែលជាអ្នកនេសាទបានឲ្យដឹងថា ប្រជាពលរដ្ឋចេញទៅនេសាទនៅរដូវប្រាំង ដែលក្នុងនោះមានប្រជាពលរដ្ឋចេញទៅនេសាទជាប្រចាំថ្ងៃមានចំនួន20.21%ចេញទៅនេសាទដែលមានរយៈពេលពី21-29ថ្ងៃមានចំនួន11.70% ចេញទៅនេសាទតិចជាង20ថ្ងៃមានចំនួន51.07% ហើយប្រជាពលរដ្ឋមិនបានផ្តល់ចំលើយមានចំនួន17.02%។

តារាង 4.29 តារាងស្តីពីចំនួនថ្ងៃដែលប្រជាពលរដ្ឋឃុំទាំង3ចេញទៅនេសាទនៅរដូវប្រាំង

ចំនួនថ្ងៃដែលចេញទៅនេសាទ	ឃុំបឹងទូក		ឃុំកោះតូច		ឃុំព្រែកស្នោត	
	ចំនួនមនុស្ស	ភាគរយ	ចំនួនមនុស្ស	ភាគរយ	ចំនួនមនុស្ស	ភាគរយ
តិចជាង 20ថ្ងៃ	5	18.52	39	41.49	48	51.07
ចាប់ពី 21-29ថ្ងៃ	2	7.41	20	21.28	11	11.70
នេសាទរៀងរាល់ថ្ងៃ	3	11.11	18	19.15	19	20.21
មិនផ្តល់ចំលើយ	17	62.96	17	18.08	16	17.02
សរុប	27	100	94	100	94	100

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ (ខែមីនា ឆ្នាំ 2010)

<u>ចំនួនថ្ងៃនៃការនេសាទនៅរដូវវស្សា</u>

យោងទៅតាមលទ្ធផលនៃការសម្ភាសន៍ជាមួយប្រជាពលរដ្ឋឃុំបឹងទូកចំនួន59.30% ដែលជាអ្នកនេសាទបានឲ្យដឹងថា ប្រជាពលរដ្ឋដែលចេញទៅនេសាទនៅរដូវវស្សា គឺចាប់ពីខែឧសភា ដល់ខែតុលា ដែលក្នុងនោះមានប្រជាពលរដ្ឋចេញទៅនេស្ទាជាប្រចាំថ្ងៃមានចំនួន11.11% ចេញទៅនេសាទដែលមានរយៈពេលពី21-29ថ្ងៃមានចំនួន 7.41% ហើយចេញទៅនេសាទតិចជាង20ថ្ងៃមានចំនួន18.52%។ ដោយឡែក ប្រជាពលរដ្ឋមិនបានផ្តល់ចំលើយមានចំនួន 62.96% ដូចបង្ហាញជូនក្នុងតារាង 4.30។

ចំណែក ប្រជាពលរដ្ឋឃុំកោះតូចវិញមានចំនួន 77.66% ដែលជាអ្នកនេសាទបានឲ្យដឹងថា ប្រជាពលរដ្ឋ ដែលចេញទៅនេសាទនៅរដូវវស្សា ដែលក្នុងនោះមានប្រជាពលរដ្ឋចេញទៅនេសាទជាប្រចាំថ្ងៃ មានចំនួន14.89% ចេញទៅនេសាទដែលមានរយៈពេលពី21-29ថ្ងៃមានចំនួន17.02% ចេញទៅនេសាទតិចជាង20ថ្ងៃ មានចំនួន45.75% ហើយប្រជាពលរដ្ឋមិនបានផ្តល់ចំលើយមានចំនួន 22.34%។

ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋឃុំព្រែកស្នោតមានចំនួន 77.66% ដែលជាអ្នកនេសាទបានឲ្យដឹងថា ប្រជាពលរដ្ឋ ចេញទៅនេសាទនៅរដូវវស្សា ដែលក្នុងនោះមានប្រជាពលរដ្ឋចេញទៅនេសាទជាប្រចាំថ្ងៃ មានចំនួន 20.21% ចេញទៅ នេសាទដែលមានរយៈពេលពី21-29ថ្ងៃមានចំនួន9.58% ចេញទៅនេសាទតិចជាង 20ថ្ងៃមានចំនួន 50.00% ហើយ ប្រជាពលរដ្ឋមិនបានផ្តល់ចំលើយមានចំនួន 20.21%។

តារាង 4.30 តារាងស្តីពីចំនួនថ្ងៃដែលប្រជាពលរដ្ឋយុំទាំងបីចេញទៅនេសាទនៅរដូវវស្សា

ចំនួនថ្ងៃដែលចេញទៅនេសាទ	យុំបឹងទូក		យុំកោះតូច		យុំព្រែកត្នោត	
	ចំនួនមនុស្ស	ភាគរយ	ចំនួនមនុស្ស	ភាគរយ	ចំនួនមនុស្ស	ភាគរយ
តិចជាង 20ថ្ងៃ	5	18.52	43	45.75	47	50.00
ចាប់ពី 21-29ថ្ងៃ	2	7.41	16	17.02	9	9.58
នេសាទរៀងរាល់ថ្ងៃ	3	11.11	14	14.89	19	20.21
មិនផ្តល់ចំលើយ	17	62.96	21	22.34	19	20.21
សរុប	27	100	94	100	94	100

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ (ខែមីនា ឆ្នាំ 2010)

ជារួម លទ្ធផលនៃការសិក្សាទៅលើចំនួនថ្ងៃនៃប្រជានេសាទរបស់យុំទាំង3ចេញទៅនេសាទទាំងរដូវប្រាំង និងរដូវវស្សាបានបង្ហាញឲ្យឃើញថា ប្រជានេសាទចេញទៅនេសាទជារៀងរាល់ថ្ងៃដោយមិនគិតថារដូវប្រាំង ឬរដូវវស្សាឡើយ ដែលក្នុងនោះយុំបឹងទូកមានចំនួន11.11% និងយុំព្រែកត្នោតមានចំនួន20.21%។ ដោយឡែក ការចេញនេសាទជារៀងរាល់ថ្ងៃនៅរដូវប្រាំងរបស់ប្រជានេសាទយុំកោះតូច មានចំនួន19.15% ច្រើនជាងការចេញទៅនេសាទនៅរដូវវស្សា ដែលមានចំនួន14.89%។

<u>☞ប្រាក់ចំណូលពីការនេសាទ</u>

យោងទៅតាមតារាង4.26បង្ហាញឲ្យឃើញថា ការនេសាទជាមុខរបរចំបងនៅក្បែរតំបន់គំរោង ដែលក្នុងនោះ យុំបឹងទូកមាន59.30% យុំកោះតូចមាន77.66% និងព្រែកត្នោតមាន77.66%។

ចំងាយដែលប្រជានេសាទចេញទៅនេសាទ គឺអាស្រ័យទៅលើប្រភពធនធាន និងប្រភេទទូក។ ឆ្លងតាមការស្រាវជ្រាវបង្ហាញថា ប្រជាពលរដ្ឋនៅក្នុងភូមិក្បែរទីតាំងគំរោងបានចេញនេសាទក្នុងចំងាយជាមធ្យម1គ.ម ពីប្រាំងចំពោះប្រជានេសាទដែលប្រើទូកចែវ និងមានចំងាយលើសពី4គ.មចំពោះទូកម៉ាស៊ីនដែលមានកំលាំង6សេស។ ចំពោះគ្រួសារណាដែលមានជីវភាពធូរធារ គឺមានទូកអុំ ឬចែវ ឬទូកម៉ាស៊ីនដែលមានលក្ខណៈផ្តល់ភាពងាយស្រួលអាចទៅនេសាទបានឆ្ងាយ។ ឧបករណ៍ដែលប្រជាពលរដ្ឋយកទៅនេសាទតាមទូកមានដូចជា លបក្តាម លបបង្គា មងអូសជាដើម ហើយប្រជាពលរដ្ឋមួយចំនួន ប្រើប្រាស់ឈឹប ធ្នស់ជាដើមនៅតំបន់ទឹករាក់ និងរកដោយដៃនៅតាមតំបន់ក្បែរច្រាំង (រូបភាពក្នុងឧបសម្ព័ន្ធ5ចំនុច5.3)។ ចំពោះពេលវេលានៃការចេញទូកនេសាទវិញ គឺពេញមួយថ្ងៃ ឬពេញមួយយប់ គឺអាស្រ័យទៅនឹងទឹកនាច ឬទឹកជោរ។ ជាក់ស្តែង នៅតំបន់គំរោងក្រុមការងារប្រទះឃើញ ទូកនេសាទបង្គា មឹកធ្វើសកម្មភាពទាំងថ្ងៃទាំងយប់ ហើយប្រទះឃើញមានការរកត្រីនៅតាមរន្តថ្មក្បែរព្រែកក្តាត និងការរកគ្រែងឈាមនៅទីតាំងដែលបានចាក់បំពេញ(រូបភាព4.2ទីតាំងB2)ផងដែរ ដែលប្រជានេសាទបានបញ្ជាក់ថាសកម្មភាពនេះ ទើបឃើញមានជាលើកដំបូងនៅប្រមាណ2ថ្ងៃមុនការចុះសិក្សាទេ។ ចំពោះឧបសគ្គពេលចេញទូកនេសាទគឺអាកាសធាតុក្តៅ ខ្យល់ព្យុះ ភ្លៀង ឬអត់ងងុយពេញមួយយប់។

ប្រជានេសាទ នៅក្បែរទីតាំងគំរោងលក់ផលនេសាទទៅឲ្យឈ្មួញកណ្តាលក្នុងតំលៃមួយ ដែលកំណត់ ដោយឈ្មួញកណ្តាលផ្ទាល់។ ឈ្មួញកណ្តាលតម្រូវឲ្យប្រជានេសាទលក់ផលនេសាទ ឲ្យខ្លួន ជាថ្នូរនឹងការផ្តល់ ប្រាក់កម្ចី សំរាប់ទិញឧបករណ៍នេសាទនៅពេលដែលគាត់ខ្វះខាតថវិកា។ ប្រជានេសាទខ្លះ ចូលទូក និងធ្វើការដោះដូរនៅលើផ្លូវចាក់ក្នុងតំបន់ចាក់បំពេញ(រូបភាពក្នុងឧបសម្ព័ន្ធ5ចំនុច5.3)។

ជាទូទៅប្រជានេសាទដែលបានផ្តល់សម្ភាសន៍អាចរកប្រាក់ពីការនេសាទបានជាមធ្យមចាប់ពី 1,200រៀលទៅដល់365,000រៀលក្នុងមួយថ្ងៃ ដែលក្នុងនោះមានប្រជាពលរដ្ឋនៅក្បែរតំបន់គំរោងប្រមាណ32.09%អាចរកបានជាមធ្យមក្នុងមួយថ្ងៃក្រោម10,000រៀល។

តារាង 4.31 បង្ហាញពីប្រាក់ចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋឃុំទាំង3 ដែលរកប្រាក់ក្នុងមួយថ្ងៃពីការនេសាទ ដែលក្នុងនោះ៖

(1)-ប្រជាពលរដ្ឋឃុំបឹងទូក៖
- អាចរកប្រាក់បានជាមធ្យមក្រោម 10,000រៀល មានចំនួន 40.74%
- អាចរកប្រាក់បានជាមធ្យមចាប់ពី 10,000-20,000រៀល មានចំនួន 14.81%
- អាចរកប្រាក់បានជាមធ្យមចាប់ពី 20,000-40,000រៀល មានចំនួន 11.11%
- អ្នកមិនផ្តល់ចំលើយ មានចំនួន 33.34%

(2)-ប្រជាពលរដ្ឋឃុំកោះតូច៖
- អាចរកប្រាក់បានជាមធ្យមក្រោម 10,000រៀល មានចំនួន 25.53%
- អាចរកប្រាក់បានជាមធ្យមចាប់ពី 10,000-20,000រៀល មានចំនួន 17.02%
- អាចរកប្រាក់បានជាមធ្យមចាប់ពី 20,000-40,000រៀល មានចំនួន 12.77%
- អាចរកប្រាក់បានជាមធ្យមច្រើនជាង 40,000រៀល មានចំនួន 15.96%
- អ្នកមិនផ្តល់ចំលើយ មានចំនួន 28.72%

(3)-ប្រជាពលរដ្ឋឃុំព្រែកស្នោតៈ
- អាចរកប្រាក់បានជាមធ្យមក្រោម 10,000រៀល មានចំនួន 36.17%
- អាចរកប្រាក់បានជាមធ្យមចាប់ពី 10,000-20,000រៀល មានចំនួន 13.83%
- អាចរកប្រាក់បានជាមធ្យមចាប់ពី 20,000-40,000រៀល មានចំនួន 5.32%
- អាចរកប្រាក់បានជាមធ្យមច្រើនជាង 40,000រៀល មានចំនួន 13.83%
- អ្នកមិនផ្តល់ចំលើយ មានចំនួន 30.85%

តារាង 4.31 តារាងស្តីពីប្រាក់ចំណូលជាមធ្យមពីផលនេសាទ៍ក្នុងមួយថ្ងៃរបស់ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍

ប្រាក់ចំណូល (រៀល)	ឃុំបឹងទូក		ឃុំកោះតូច		ឃុំព្រែកស្នោត		សរុប	
	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ	ចំនួននាក់	ភាគរយ
តិចជាង 10,000	11	40.74	24	25.53	34	36.17	69	32.09
10,000-20,000	4	14.81	16	17.02	13	13.83	33	15.35
20,000-40,000	3	11.11	12	12.77	5	5.32	20	9.30
ច្រើនជាង 40,000	0	0	15	15.96	12	12.77	27	12.56
មិនផ្តល់ចំលើយ	9	33.34	27	28.72	30	31.91	66	30.70
សរុប	27	100	94	100	94	100	215	100

ប្រភព៖ តាមការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋ (ខែមីនា ឆ្នាំ 2010)

តាមរយៈការជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋបានឲ្យដឹងថា ក្រៅពីដាំស្រូវ ប្រជាពលរដ្ឋចិញ្ចឹមសត្វដើម្បីទុកជាកំលាំងអូសទាញ និងសំរាប់ទុកធ្វើជាម្ហូបអាហារ និងលក់ផ្តត់ផ្តង់ជីវភាពគ្រួសារ ។ សត្វសំរាប់កំលាំងអូសទាញ ដូចជា

គោ ក្របី ជាដើម។ ចំណែកការចិញ្ចឹមសត្វសំរាប់លក់ និងទុកធ្វើជាម្ហូបអាហាររួមមាន ជ្រូក មាន់ ទា ជាដើម។ ប្រជាពលរដ្ឋក្នុងភូមិក៏បានដាំដំណាំរួមផ្សំផងដែរដូចជា ឪឡឹក ត្រកួន ត្រាវ ចេក អំពៅ ស្វាយ ដូង ល្ពង...។

☞ ការដាំសារាយរបស់ប្រជាជននៅក្បែរតំបន់គំរោង

នៅប្រមាណ1គីឡូម៉ែត្រពីតំបន់ចាក់បំពេញ មានកសិដ្ឋានដាំសារាយរបស់ប្រជាពលរដ្ឋដែលកសិដ្ឋាននេះលាតសន្ធឹងទៅទិសខាងលិចរហូតដល់ជិតព្រែកក្តាត។ តាមរបាយការណ៍សំណង់ផែ និងការបូមស្តារនៅក្នុងខេត្តកំពត ម៉ូដែលលេខ និងការវាយតំលៃបឋមអំពីផលប៉ះពាល់ ខែសីហា ឆ្នាំ2006បានបញ្ជាក់ថា កសិដ្ឋានដាំសារាយរបស់ប្រជាពលរដ្ឋមានទំហំប្រមាណ3,000ហ.ត និងប្រជាពលរដ្ឋប្រមាណ2,000គ្រួសារដែលដាំសារាយ ហើយពូជសារាយដែលប្រជាពលរដ្ឋដាំមានឈ្មោះថា *Eucheuma cottonii*[30]។

ជាមួយគ្នានេះដែរ យោងតាមការសិក្សារបស់ក្រុមការងារស៊ី អ៊ី អេស ចាប់ពីថ្ងៃទី27 ខែកុម្ភៈ ដល់ថ្ងៃទី03 ខែមិនា ឆ្នាំ2010 តាមរយៈការសម្ភាសន៍ជាមួយលោកមេភូមិនៅតំបន់គោលដៅនៃឃុំកោះតូចបានឲ្យដឹងថា បច្ចុប្បន្នប្រជាពលរដ្ឋដែលដាំសារាយមានតែនៅបីភូមិនៃឃុំកោះតូច ដែលក្នុងនោះ៖

-ភូមិព្រែកចេកមានចំនួន7គ្រួសារស្មើនឹង5%នៃប្រជាពលរដ្ឋក្នុងភូមិ
-ភូមិកណ្តាលមានចំនួន120គ្រួសារស្មើនឹង61%នៃប្រជាពលរដ្ឋក្នុងភូមិ
-ភូមិព្រែកអំពិលមានចំនួន20គ្រួសារស្មើនឹង5%នៃប្រជាពលរដ្ឋក្នុងភូមិ

លើសពីនេះទៅទៀត តាមរយៈការសម្ភាសន៍ជាមួយប្រជាពលរដ្ឋនៃឃុំកោះតូចចំនួន94នាក់បានបង្ហាញផងដែរថា ក្រៅពីមុខរបរចំបង(ការនេសាទ និងធ្វើស្រែ) មុខរបរដាំសារាយរបស់ប្រជាពលរដ្ឋនៅភូមិទាំងបីខាងលើគឺជាមុខរបរបន្ទាប់បន្សំដែលក្នុងនោះ៖ ភូមិព្រែកចេកមាន01គ្រួសារស្មើនឹង10% នៃប្រជាពលរដ្ឋដែលបានសម្ភាសន៍ ភូមិកណ្តាលមាន5គ្រួសារ ស្មើនឹង36%នៃប្រជាពលរដ្ឋដែលបានសម្ភាសន៍ និងភូមិព្រែកអំពិលមាន20គ្រួសារ ស្មើនឹង65%នៃប្រជាពលរដ្ឋដែលបានសម្ភាសន៍។

យោងតាមការកំណត់កសិដ្ឋានដាំសារាយរបស់ក្រុមការងារដោយប្រើប្រព័ន្ធGPSបានបង្ហាញថា ទីតាំងមានបង្គោលដាំសារាយមានទំហំប្រមាណ1,260ហិកតា ក៏ប៉ុន្តែក្រលាផ្ទៃជាក់ស្តែងមានទំហំតូចជាងនេះ (ចំណុច 4.2.2.2.4)។

តាមការសាកសួរព័ត៌មានពីអ្នកដាំសារាយបានឲ្យដឹងថាកសិដ្ឋាននេះកកើតនៅឆ្នាំ1999 ដោយក្រុមហ៊ុនម៉ាឡេស៊ីមួយឈ្មោះStar Private បានផ្តល់ពូជ និងប្រមូលទិញផលសារាយពីប្រជាពលរដ្ឋ។ ប៉ុន្តែមកដល់ឆ្នាំ2004 ក្រុមហ៊ុនបានឈប់ផ្តល់ពូជ និងឈប់ទិញផលសារាយពីប្រជាពលរដ្ឋ ហើយចាប់ពីពេលនោះមកប្រជាពលរដ្ឋរកទិញពូជដោយខ្លួនឯង ឬដាំបង្កើតពូជដោយខ្លួនឯង រីឯផលដែលដាំបានភាគច្រើនពួកគាត់លក់ឲ្យឈ្មួញវៀតណាម។ ចំនួនប្រជាពលរដ្ឋដាំសារាយបច្ចុប្បន្ន មានការថយចុះ ដោយសារអាកាសធាតុក្តៅពេកធ្វើឲ្យសារាយរលួយ ពូជក្លាយ ការចាក់ដីលុបរបស់ក្រុមហ៊ុនដើម្បីសង់កំពង់ផែ ដែលបង្កឲ្យមានបញ្ហាទឹកល្អក់អាចបណ្តាលឲ្យសារាយលូតលាស់មិនល្អ(ក្រិន) ហើយម្យ៉ាងទៀតមានត្រីស៊ីទៀតផង។ ក្នុងមួយឆ្នាំៗ ជាទូទៅប្រជាពលរដ្ឋដាំសារាយបានរយៈពេលប្រហែល3ខែ គឺពីខែកញ្ញាដល់ខែធ្នូ។

ចំណែកវិធីដាំសារាយវិញ គឺគេដាំបង្គោលក្នុងទឹក(បង្គោលនីមួយៗមានប្រវែងប្រមាណ4.5ម) ហើយសារាយដែល ត្រូវដាំត្រូវបានចងភ្ជាប់នឹងខ្សែ បន្ទាប់មកខ្សែនោះត្រូវបានចងនឹងបង្គោល ដែលខ្សែនោះមានជម្រៅប្រមាណ0.5-1.5ម ពីផ្ទៃទឹក។

[30]ឯកសារយោង8

ចំពោះតំលៃសាយសំរាប់ធ្វើពូជដែលគាត់ទិញគឺពី800 ទៅ1,000រៀល/គ.ក។ រីឯតំលៃលក់ចេញវិញ មានការប្រែប្រួលពី300-400រៀល/គីឡូក្រាម ចំពោះសាយសើម និង4,000រៀល/គីឡូក្រាម ចំពោះសាយស្ងួត។

គ-ការប្រើប្រាស់ដី

គ.1- ឃុំបឹងទូក

យោងតាមទិន្នន័យឃុំបឹងទូក (ប្រភព៖ សៀវភៅទិន្នន័យឃុំ-សង្កាត់ ឆ្នាំ2009) បានបញ្ជាក់ថា ផ្ទៃដីសរុបសំរាប់ដាំស្រូវវស្សារបស់ឃុំមានចំនួន 97ហិកតា ហើយពុំមានផ្ទៃដីសំរាប់ដាំស្រូវប្រាំងទេ។ ជាមួយគ្នានេះដែរ យោងតាមតារាង 4.26បានបង្ហាញថា ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ចំនួន27នាក់ មានប្រជាពលរដ្ឋប្រមាណ14.80%ប្រកបមុខរបរកសិកម្ម។ ជារួម នៅឆ្នាំ2008ទិន្នផលស្រូវវស្សាជាមធ្យមក្នុងផ្ទៃដី1ហិកតា ទទួលបានផលប្រមាណ3តោន ដូចនេះ ប្រជាពលរដ្ឋឃុំបឹងទូកបានទទួលទិន្នផលស្រូវវស្សាជាមធ្យមចំនួន 291តោន។ ចំណែកស្រូវក្នុង1គីឡូក្រាមលក់បានក្នុង តំលៃចន្លោះពី 600-900រៀល។

ក្រៅពីការប្រកបមុខរបរធ្វើស្រែវស្សា ប្រជាពលរដ្ឋមួយចំនួនធ្វើការដាំដុះដំណាំចំការ ដូចជា ដាំពោត សណ្តែកដី ដំឡូងមី ដំឡូងជ្វា ។ល។ ដូចមានបង្ហាញជូននៅក្នុងតារាង 4.32។

តារាង 4.32 តារាងស្តីពីការប្រើប្រាស់ដីចំការ និងទិន្នផលសរុប

ល.រ	ប្រភេទដំណាំ	ផ្ទៃដីដាំដុះ (ហ.ត)	ទិន្នផល (តោន)	ទិន្នផលសរុប (តោន)
1	ពោត	6	3	18
2	សណ្តែកដី	0.5	1	0.5
3	ដំឡូងមី	1	5	5
4	ដំឡូងជ្វា	1	3	3

ប្រភព៖ ទិន្នន័យឃុំបឹងទូក ឆ្នាំ2009

គ-2. ឃុំកោះតូច

យោងតាមទិន្នន័យឆ្នាំ2008 របស់ឃុំកោះតូច (ប្រភព៖ សៀវភៅទិន្នន័យឃុំ-សង្កាត់ ឆ្នាំ2009) បានបញ្ជាក់ថា ប្រជាពលរដ្ឋចំនួន662គ្រួសារ ក្នុងចំណោមប្រជាពលរដ្ឋសរុបទូទាំងឃុំចំនួន1,284គ្រួសារ ប្រកបមុខរបរកសិកម្មនៅលើផ្ទៃដីស្រូវវស្សាសរុបចំនួន252ហិកតា(ពុំមានផ្ទៃដីស្រូវប្រាំងទេ) ហើយផ្ទៃដីស្រូវចំការមានចំនួន2ហិកតា។ ជាមួយគ្នានេះដែរ យោងតាមតារាង 4.26បានបង្ហាញថា ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ចំនួន94នាក់ មានប្រជាពលរដ្ឋប្រមាណ11.70% ប្រកបមុខរបរកសិកម្ម។ ជារួម នៅឆ្នាំ2008ទិន្នផលស្រូវវស្សា និងស្រូវចំការជាមធ្យមក្នុងផ្ទៃដី1ហិកតា ទទួលបានផលប្រមាណ1.5តោន។ ដូចនេះ ប្រជាពលរដ្ឋឃុំកោះតូចបានទទួលទិន្នផលស្រូវវស្សាជាមធ្យមចំនួន378តោន និងទិន្នផលស្រូវចំការទទួលបាន3តោន។ ចំណែកស្រូវក្នុង1គីឡូក្រាមលក់បានក្នុងតំលៃពី 563-800រៀល។

គ-3. ឃុំព្រែកស្នោត

យោងតាមទិន្នន័យឆ្នាំ2008របស់ឃុំព្រែកស្នោត (ប្រភព៖ សៀវភៅទិន្នន័យឃុំ-សង្កាត់ ឆ្នាំ2009) បានបញ្ជាក់ថា ប្រជាពលរដ្ឋចំនួន608គ្រួសារក្នុងចំណោមប្រជាពលរដ្ឋសរុបទូទាំងឃុំចំនួន1704គ្រួសារ ប្រកបមុខរបរកសិកម្មនៅលើផ្ទៃដីស្រូវវស្សាសរុបចំនួន571ហិកតា(ពុំមានផ្ទៃដីស្រូវប្រាំងទេ)។ ជាមួយគ្នានេះដែរ យោងតាមតារាង 4.26បានបង្ហាញថា ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ចំនួន94នាក់ មានប្រជាពលរដ្ឋប្រមាណ14.80%ប្រកបមុខរបរកសិកម្ម។ ជារួម នៅឆ្នាំ2008ទិន្នផលស្រូវវស្សាជាមធ្យមក្នុងផ្ទៃដី1ហិកតា ទទួលបានផលប្រមាណ1.5តោន។ ដូចនេះ ប្រជាពលរដ្ឋ

ឃុំព្រែកស្នោតបានទទួលទិន្នផលស្រូវរៃស្យាជាមធ្យមចំនួន856.5តោន។
ចំណែកស្រូវក្នុង1គីឡូក្រាមលក់បានក្នុងតំលៃពី675-1,050រៀល។

ឃ- ការប្រើប្រាស់ទឹក

ប្រជាពលរដ្ឋក្នុងភូមិក្បែរតំបន់គំរោងប្រើប្រាស់ទឹកដែលមានប្រភព6ខុសៗគ្នាដូចជា អណ្តូងស្នប់ ឬអណ្តូងចំរុះ អណ្តូងលូ អណ្តូងជីកដៃមិនដាក់លូ ឬមិនរៀបឥដ្ឋ ទឹកស្រះ ទឹកភ្លៀង និងទិញទឹក។ តាមរយៈទិន្នន័យឃុំបានបញ្ជាក់ថា អណ្តូងក្នុងឃុំទាំង3ដែលក្បែរនឹងតំបន់គំរោងមានចំនួន 732 (គ្រប់ប្រភេទអណ្តូងទាំងអស់) និងស្រះទឹកដែលប្រជាពលរដ្ឋ ប្រើប្រាស់មានចំនួន49។ ក្នុងចំណោមអណ្តូងទាំងអស់ មានអណ្តូងមួយចំនួនមិនអាចប្រើប្រាស់បានទេ ដោយសារមិនចេញទឹកនៅរដូវប្រាំង និងការជ្រាបចូលនូវទឹកប្រៃ ជាពិសេសនៅភូមិគីឡូ12 ដែលជាហេតុធ្វើឲ្យប្រជាពលរដ្ឋត្រូវទិញទឹកដើម្បីទុកប្រើប្រាស់ប្រចាំថ្ងៃ។ ជាទូទៅ ប្រជាពលរដ្ឋដែលប្រើទឹកអណ្តូងត្រូវធ្វើដំណើរចំងាយ 200ម៉ែត្រ (គិតទាំងទៅទាំងមក) ដើម្បីទទួលបានទឹកមកប្រើប្រាស់។ តាមរយៈទិន្នន័យខាងលើ ប្រជាពលរដ្ឋប្រើប្រាស់ទឹកអណ្តូងច្រើនជាងគេ ហើយលទ្ធភាពដែលប្រជាពលរដ្ឋទទួលបានបណ្តាញទឹកស្អាតនៅពុំទាន់មាននៅឡើយ។ តារាង 4.33 ខាងក្រោមនេះបង្ហាញអំពីចំនួនអណ្តូងដែលអាចប្រើប្រាស់បានពេញមួយឆ្នាំនៅតាមភូមិ។

តារាង 4.33 ចំនួនអណ្តូងសរុបដែលមាននៅតាមភូមិ

ភូមិ	អណ្តូងលូ	អណ្តូងស្នប់ ឬចំរុះ	អណ្តូងដៃមិនដាក់លូ ឬមិនរៀបឥដ្ឋ	ស្រះទឹក	សរុប
1. ឃុំបឹងទូក					
រលួស	118	0	1	0	119
2. ឃុំកោះតូច					
គីឡូ12	84	95	0	0	179
ព្រែកចេក	28	36	5	0	69
កណ្តាល	15	19	5	0	39
ព្រែកអំពិល	50	46	25	2	123
3. ឃុំព្រែកស្នោត					
ត្រពាំងរពៅ	15	24	4	1	44
ព្រែកក្រែង	28	43	12	0	83
ព្រែកអំពិល	8	11	1	3	23
ចង្ហោន	26	33	0	43	102
សរុប	**372**	**307**	**53**	**49**	**781**

ប្រភព៖ សៀវភៅទិន្នន័យឃុំ ឆ្នាំ2009

ង-ការប្រើប្រាស់ថាមពល

ប្រជាពលរដ្ឋក្នុងភូមិក្បែរតំបន់គំរោងប្រើប្រាស់អុសសំរាប់ចំអិនអាហារ និងមានការចំណាយតិចតួចបំផុតលើថ្លៃអុស ដោយសារតែទីតាំងភូមិសាស្ត្ររបស់ភូមិក្បែរនឹងភ្នំបូកគោ និងព្រៃកោងកោង។ ប្រជាពលរដ្ឋអាចកាប់ឈើងាប់ៗ សំរាប់ទុកប្រើប្រាស់ក្នុងគ្រួសារ។

ចំពោះការប្រើប្រាស់ថាមពលសំរាប់បំភ្លឺគេហដ្ឋានវិញ នៅក្នុងភូមិនៅមានសភាពខ្វះខាតនៅឡើយ។ នៅតាមភូមិភាគច្រើនគ្មានការតបណ្តាញអគ្គិសនី ឬផ្គត់ផ្គង់អគ្គិសនីដោយឯកជននោះទេ។ ចំពោះប្រជាពលរដ្ឋនៅភូមិដែលមានជីវភាពធូរធារបន្តិច គឺប្រើប្រាស់អាគុយ និងចង្កៀងជាថាមពលបំភ្លឺ ហើយប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រគឺប្រើប្រាស់ចង្កៀងប្រេងកាតប៉ុណ្ណោះ។ ដោយឡែក នៅតាមផ្លូវជាតិ3នាពេលថ្មីៗនេះ មានប្រជាពលរដ្ឋមួយចំនួន បានតទម្លាក់ពីខ្សែបណ្តាញគោលដែលតពីក្រុងកំពត។

ច-ការអប់រំ

ច-1.ការអប់រំ

ការអប់រំមានសារៈសំខាន់ណាស់សម្រាប់កសាងនូវធនធានមនុស្ស។ ចំណែកការអប់រំនៅពេលនេះ គឺសំដៅទៅលើការសិក្សាអប់រំរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោងប៉ុណ្ណោះ។ ប្រសិនបើនៅក្នុងតំបន់មួយសំបូរទៅដោយអ្នកចេះដឹងច្រើន នោះនាំឲ្យតំបន់នោះមានការរីកចំរើន រីឯប្រជាពលរដ្ឋក៏មានជីវភាពធូរធារផងដែរ។ ស្របពេលជាមួយគ្នានេះដែរ នៅពេលគំរោងមានដំណើរការ គំរោងអាចជួយលើកស្ទួយវិស័យសិក្សាធិការនៅក្នុងតំបន់តាមរយៈការជួយសាងសង់សាលារៀន និងអាចផ្តល់ការងារដល់ប្រជាពលរដ្ឋដែលមានចំណេះដឹង និងសមត្ថភាពចូលបម្រើការងារឲ្យគំរោងថែមទៀតផង។ តារាង4.34បង្ហាញអំពីចំនួនប្រជាពលរដ្ឋដែលមានអាយុចាប់ពី6-24ឆ្នាំ កំពុងរៀននៅសាលាចំណេះទូទៅ និងមហាវិទ្យាល័យ ព្រមទាំងបង្ហាញអំពីចំនួនប្រជាពលរដ្ឋដែលមានអាយុចាប់ពី15-60ឆ្នាំដែលជាអ្នកមិនចេះអក្សរ។

តារាង 4.34 ចំនួនប្រជាពលរដ្ឋកំពុងរៀននៅសាលាចំណេះទូទៅ និងមហាវិទ្យាល័យ និងចំនួនអនក្ខរជន

ឃុំ	ភូមិ	ប្រជាពលរដ្ឋកំពុងរៀននៅ (នាក់)		
		ចំនួនប្រជាពលរដ្ឋសរុប	ចំនួនប្រជាពលរដ្ឋកំពុងរៀន	ចំនួនអនក្ខរជន
ឃុំបឹងទូក	រលួស	1,612	753	120
ឃុំកោះតូច	គីឡូ12	2,859	599	145
	ព្រែកចេក	814	241	31
	កណ្តាល	992	240	47
	ព្រែកអំពិល	2,033	450	78
ឃុំព្រែកត្នោត	ត្រពាំងរពៅ	3,688	765	345
	ព្រែកក្រែង	1,668	327	424
	ព្រែកត្នោត	1,583	708	245
	ចង្ហោន	1,829	412	195

ប្រភព៖ សៀវភៅទិន្នន័យឃុំ ឆ្នាំ2009

តាមទិន្នន័យខាងលើបង្ហាញថា ប្រជាពលរដ្ឋមិនចេះអក្សរជាប្រជាពលរដ្ឋដែលមានវ័យចាស់ ព្រោះពួកគាត់មិនអាចមានឱកាសចូលរៀនដោយសារបញ្ហាសង្ត្រាម។ ដោយសារស្ថានភាពសន្តិសុខសង្គមមានលក្ខណៈល្អប្រសើរជាងមុននោះ ធ្វើឲ្យឱកាសទទួលបានការអប់រំមានការកើនឡើង។ តាមតារាងខាងលើអាចសន្និដ្ឋានបានថា ប្រជាពលរដ្ឋក្នុងតំបន់មានឱកាសច្រើន ដើម្បីចូលបម្រើការងារក្នុងគំរោង ដោយអាស្រ័យទៅតាមកំរិតអប់រំ និងជំនាញផ្ទាល់ខ្លួនរបស់គាត់។

ច-2. សាលារៀន

សាលារៀន គឺជាកន្លែងបណ្តុះចំណេះវិជ្ជាដល់ប្រជាពលរដ្ឋនៅក្នុងតំបន់។ ចំពោះសាលារៀននៅក្នុងឃុំបឹងទូក និង ឃុំកោះតូច គឺមានត្រឹមតែអនុវិទ្យាល័យតែប៉ុណ្ណោះ ដែលតំរូវឲ្យកូនសិស្សទៅរៀននៅឃុំព្រែកគ្នោតដែលមានចំងាយ ជា មធ្យមប្រមាណ15-22គ.ម។ ចំណែកឃុំបឹងទូកមានសាលាបឋមសិក្សាចំនួន03 និងអនុវិទ្យាល័យចំនួន01 ដែលមានបន្ទប់សរុបទាំងអស់ចំនួន26បន្ទប់។ រីឯឃុំកោះតូចវិញមានសាលាបឋមសិក្សាមានចំនួន04 និងអនុវិទ្យាល័យចំនួន01 ស្មើនឹង27បន្ទប់។ ដោយឡែក យោងតាមទិន្នន័យរបស់ឃុំព្រែកគ្នោតបានឲ្យដឹងថា មានសាលាបឋមសិក្សាចំនួន07 អនុវិទ្យាល័យចំនួន02 និងវិទ្យាល័យចំនួន01 ស្មើនឹង42បន្ទប់។ តារាង4-35 បង្ហាញពីចំនួនសាលារៀនដែលមាននៅតាមបណ្តាឃុំដែលជាប់ពាក់ព័ន្ធនឹងគំរោង៖

តារាង 4.35 ចំនួនសាលារៀននៅតាមបណ្តាឃុំទាំង3

ឃុំ	សាលារៀនតាមបណ្តាឃុំ			សរុបចំនួនបន្ទប់
	សាលាបឋមសិក្សា	សាលាអនុវិទ្យាល័យ	សាលាវិទ្យាល័យ	
ឃុំបឹងទូក	3	1	0	26
ឃុំកោះតូច	4	1	0	32
ឃុំព្រែកគ្នោត	7	2	1	42
សរុប	14	4	1	100

ប្រភព៖ សៀវភៅទិន្នន័យឃុំ ឆ្នាំ2009

ឆ. សុខភាពសាធារណៈ

ឆ-1. ការថែទាំសុខភាព

ជំងឺជាបញ្ហាមួយចោទចំពោះសុខភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ ហើយប្រភេទជំងឺដែលកើតឡើងចំពោះ ពួកគាត់ មានដូចជា៖ ជំងឺរលាកក្រពះ លើសឈាម រលាកពោះវៀន គ្រុនពោះវៀន និងផ្តាសាយជាដើម។ នៅពេលមានជំងឺ ប្រជាពលរដ្ឋទៅព្យាបាលនៅមណ្ឌលសុខភាព ពេទ្យឯកជនតាមបណ្តាភូមិ និងទៅព្យាបាលនៅមន្ទីរពេទ្យខេត្ត។ ជាក់ស្តែង រនៅក្នុងឃុំកោះតូចមានមណ្ឌលសុខភាពមួយកន្លែង រីឯឃុំបឹងតូចពុំមានមណ្ឌល សុខភាពទេ ប៉ុន្តែមានមន្ទីរពេទ្យកុមារមួយកន្លែង គឺមន្ទីរពេទ្យកុមារសុន្ទាយីល។ ក្រៅពីមណ្ឌលសុខភាព ក៏មានពេទ្យឯកជន និងផ្ទះលក់ថ្នាំពេទ្យតាមភូមិដែរ។

ជាក់ស្តែងនៅក្នុងភូមិចង្ហោនមិនមានមណ្ឌលសុខភាពនោះទេ។ នៅពេលមានជំងឺធ្ងន់ធ្ងរ ប្រជាពលរដ្ឋជាធម្មតាត្រូវធ្វើដំណើរទៅមណ្ឌលសុខភាពដែលមានចំងាយពីចំណុចកណ្តាលភូមិប្រមាណ8គីឡូម៉ែត្រ។ ប្រជាពលរដ្ឋនៅក្នុងភូមិនៅតែមានជំនឿទៅលើថ្នាំបុរាណ បើទោះបីថ្នាំក្នុងភូមិទទួលបានការបណ្តុះបណ្តាលតិចតួចក៏ដោយ។ យោងតាមទិន្នន័យឃុំព្រែកគ្នោតបានបង្ហាញថា ឃុំនេះមានថ្នាំបុរាណចំនួន7នាក់ និងស្ត្រីដែលបានសំរាលកូនដោយថ្នាំបុរាណមានចំនួន118នាក់ និងពេទ្យថ្នាំចំនួន01នាក់ ដែលស្ត្រីដែលសំរាលកូនដោយពេទ្យថ្នាំមានចំនួន87នាក់សំរាប់ឆ្នាំ2008។

ចំពោះភូមិព្រែកអំពិលវិញ មានមណ្ឌលសុខភាពមួយកន្លែងឈ្មោះថា មណ្ឌលសុខភាពកោះតូចដែលមានទីតាំងស្ថិតនៅទល់មុខនឹងភូមិតាមបណ្តោយផ្លូវជាតិលេខ3។ បើទោះបីនៅក្នុងភូមិមានមណ្ឌលសុខភាពក៏ដោយ ប៉ុន្តែស្ត្រីដែលមានផ្ទៃពោះភាគច្រើននៅតែមានជំនឿទៅលើថ្នាំបុរាណ។ បើតាមទិន្នន័យភូមិបញ្ជាក់ថា ស្ត្រីចំនួន80%បានសំរាលកូនដោយថ្នាំបុរាណ និង20ភាគរយសំរាលដោយពេទ្យថ្នាំបសំរាប់ឆ្នាំ2008 ។

ឆ-2. អនាម័យ

ការទុកដាក់សំរាមគ្មានសណ្តាប់ធ្នាប់ ឬការបន្ទោបង់ពាសវាលពាសកាលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន ដូចជាការប៉ះពាល់ដល់ប្រភពទឹកដែលនៅជិត និងបរិយាកាសជុំវិញ។ កត្តាទាំងអស់នេះបណ្តាលឲ្យប៉ះពាល់ សុខភាពរបស់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ទឹក និងការទទួលយកនូវបរិយាកាសមិនល្អដែលនៅជុំវិញគាត់។ អនាម័យល្អនាំមកនូវសុខភាពល្អ និងការសន្សំសំចៃថវិកាក្នុងគ្រួសារ ដោយមិនចាំបាច់ចំណាយថវិកាក្នុងការព្យាបាលជំងឺ។ តែទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋមួយចំនួននៅតាមទីជនបទពុំសូវយកចិត្តទុកដាក់ចំពោះ បញ្ហាអនាម័យ និងការប្រើប្រាស់បង្គន់អនាម័យទេ។ យោងតាមការអង្កេតបានឲ្យដឹងថា ការទុកដាក់សំណល់ របស់ប្រជាពលរដ្ឋក្នុងតំបន់មានលក្ខណៈខុសគ្នាទៅតាមទំលាប់គ្រួសាររៀងៗខ្លួន មានគ្រួសារខ្លះមានការរាយប៉ាយ សំណល់នៅបរិវេណជុំវិញផ្ទះ ខ្លះទុកដាក់កន្លែងត្រឹមត្រូវ និងខ្លះទៀតទុកដាក់សំរាមក្នុងរណ្តៅរួចប្រមូលដុតចោល។ រីឯការប្រើប្រាស់បង្គន់អនាម័យវិញ ឃើញថាប្រជាពលរដ្ឋតាមបណ្តាភូមិនីមួយៗមានការប្រើប្រាស់នូវបង្គន់អនាម័យច្រើន ព្រោះតែពួកគាត់មានការយល់ដឹងច្រើនពីបញ្ហាអនាម័យ និងការប្រើប្រាស់បង្គន់។ ប៉ុន្តែក៏នៅមានប្រជាពលរដ្ឋមួយចំនួនតូចនៅតែមានទំលាប់មិនប្រើបង្គន់អនាម័យ និងដោយសារតែគ្រួសារខ្លះ ពុំមានលទ្ធភាពសាងសង់បង្គន់ដោយខ្លួនឯងបាន។

ជ. ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងនាវាចរ

ទីតាំងគំរោង និងភូមិដែលពាក់ព័ន្ធនឹងគំរោង គឺស្ថិតនៅតាមដងផ្លូវជាតិលេខ3 ដែលតភ្ជាប់ពីទីរួមខេត្ត កំពតឆ្ពោះទៅផ្លូវជាតិលេខ4 ត្រង់ចំណុចវាលរេញ ខេត្តព្រះសីហនុ ហើយផ្លូវនេះត្រូវបានគេចាត់ទុកជាផ្លូវមេដ៏សំខាន់សម្រាប់តំបន់គំរោង។ បណ្តាញផ្លូវគោកក្នុងបណ្តាឃុំក្បែរតំបន់គំរោងទាំងមូល ភាគច្រើនគឺជាប្រភេទផ្លូវលំដែលពុំទាន់មានការរៀបរយឲ្យបានល្អនៅឡើយទេ។ ការធ្វើដំណើរតាមម៉ូតូក៏មានការលំបាក ពីព្រោះមិនអាចជិះបានលឿន និងងាយស្រួលឡើយ។ ចំណែកការធ្វើចរាចរពីភូមិទៅទីរួមខេត្តកំពតអាចប្រព្រឹត្តទៅបានតាមរយៈផ្លូវ ដែលតភ្ជាប់ពីផ្លូវភូមិទៅផ្លូវជាតិលេខ3។ បើទោះបីជាផ្លូវក្នុងភូមិមានសភាពទ្រុឌទ្រោមក៏ដោយ ប៉ុន្តែផ្លូវប្រភេទនេះកំពុងដើរតួយ៉ាងសំខាន់ខាងផ្នែកសេដ្ឋកិច្ច។ ប្រជាពលរដ្ឋប្រើប្រាស់ផ្លូវនេះសំរាប់ធ្វើដំណើរទៅកាន់កន្លែងនេសាទ សំរាប់ចែកចាយ និងដឹកផលនេសាទ កសិផល និងទំនិញផ្សេងៗ។

ក្រៅពីការធ្វើដំណើរតាមផ្លូវគោក ប្រជាពលរដ្ឋក្នុងតំបន់ក៏អាចធ្វើដំណើរតាមផ្លូវទឹកផងដែរ ដោយប្រើប្រាស់នូវទូក នេសាទជាយានសម្រាប់នេសាទផង និងធ្វើដំណើរទៅកាន់តំបន់ផ្សេងៗដើម្បីលក់ដូរផលនេសាទផង។ ទូកគឺជាឧបរណ៍ មួយសម្រាប់នេសាទ និងជាមធ្យោបាយសម្រាប់ធ្វើដំណើរតាមផ្លូវទឹក។ ទូកដែលប្រជាពលរដ្ឋ ក្នុងតំបន់ប្រើប្រាស់មានពីរ ប្រភេទ គឺទូកចែវ និងទូកម៉ាស៊ីន។

តារាង 4.36 បង្ហាញពីទិន្នន័យឃុំប៊ឹងទូក (សំដៅលើភូមិរលួសដែលជាភូមិគោលដៅ) ឃុំកោះតូច និងឃុំព្រែកខ្នោត មានទូកចែវ-ទូកអុំចំនួន 448គ្រឿង និងទូកម៉ាស៊ីនចំនួន 395គ្រឿង សម្រាប់ធ្វើការនេសាទ។

តារាង 4.36 ចំនួនទូកចែវ ទូកអុំ និងទូកម៉ាស៊ីនសំរាប់ធ្វើការនេសាទនៅតាមបណ្តាឃុំទាំង3

បរិមាណ	ឯកតា	ឃុំប៊ឹងទូក	ឃុំកោះតូច	ឃុំព្រែកខ្នោត	សរុប
ទូកចែវ និងទូកអុំ	គ្រឿង	60	198	190	448
ទូកម៉ាស៊ីន	គ្រឿង	15	118	262	395
សរុប	គ្រឿង	75	316	452	843

ប្រភព: សៀវភៅទិន្នន័យឃុំ ឆ្នាំ2009

ឈ-ប្រពៃណី/ទំនៀមទំលាប់ និងជនជាតិ

ភូមិព្រែកអំពិលមានវត្តមួយឈ្មោះថា **វត្តព្រែកអំពិល** ដែលស្ថិតនៅខាងត្បូងផ្លូវជាតិលេខ3 ដែលតភ្ជាប់ ពីទីរួមខេត្តកំពតទៅភូមិ។ **វត្តសុវណ្ណគីរីសោភ** ចង្ហោន ស្ថិតនៅក្នុងភូមិចង្ហោន ។ វត្តនេះមានសភាពទ្រុឌទ្រោម បើប្រៀបធៀបជាមួយវត្តព្រែកអំពិល។ **វត្តរកា** ស្ថិតក្នុងភូមិគីឡូ12 និង **វត្តរង្សី** ហៅវត្តលួស ស្ថិតក្នុង ភូមិលួស។ ដោយប្រជាពលរដ្ឋក្នុងភូមិក្បែរតំបន់គំរោង ភាគច្រើនប្រកាន់ខ្ជាប់នូវព្រះពុទ្ធសាសនា វត្តទាំងបួននេះ ដើរតួនាទីជាទីសការៈដ៏សំខាន់សំរាប់ប្រជាពលរដ្ឋមូលដ្ឋានប្រារព្ធពិធីសាសនាដើម្បីសុំសេចក្តីសុខចំរើន។

ជាមួយគ្នានេះដែរ តាមរយៈការធ្វើសម្ភាសន៍ជាមួយប្រជាពលរដ្ឋចំនួន 215នាក់ បានបង្ហាញថា៖ (1)-ភូមិលួស ឃុំបឹងទូកចំនួន 27នាក់ ស្មើនឹង100% ជាជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ (2)-ឃុំកោះតូចមាន ចំនួន94នាក់ ស្មើនឹង100% ជាជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ និង (3)-ឃុំព្រែកស្នោតមានចំនួន 64នាក់ ស្មើនឹង68% ជាជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ និងចំនួន 30នាក់ ស្មើនឹង32% ជាជនជាតិខ្មែរឥស្លាម កាន់សាសនាឥស្លាម។

ញ-តំបន់ទេសចរណ៍

ខេត្តកំពតជាខេត្តមួយកំពុងអភិវឌ្ឍទាំងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការរៀបចំកែលំអសោភ័ណ្ឌភាពទីរួមខេត្តជាដើម។ ក្រៅពីនោះ មានរមណីយដ្ឋានមួយកន្លែងឈ្មោះថា Nataya Round House Coral Resort ស្ថិតនៅក្នុងភូមិព្រែកអំពិល ដែលជាមួយនឹងគំរោងអភិវឌ្ឍន៍កំពង់ផែរបស់ក្រុមហ៊ុន KAMPOT PORT CO., LTDនេះ នឹងអាចទាក់ទាញភ្ញៀវទេសចរណ៍ទាំងក្នុងស្រុក និងក្រៅស្រុកដើម្បីចូលមកកាន់ខេត្តកំពតកាន់តែច្រើនឡើង។ ជាងនេះទៅទៀត ការអភិវឌ្ឍន៍នេះអាចជួយអភិវឌ្ឍន៍ដល់ខេត្តជួយលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិថែមទៀតផង។

ដ-សហគមន៍នេសាទ និងសហគមន៍ការពារស្មៅសមុទ្រ

ទីតាំងស្ពារឃ្លងនាវាចេញ-ចូល ស្ថិតនៅក្បែរឃុំព្រែកស្នោតដែលមានសហគមន៍ចំនួន3 គឺសហគមន៍នេសាទពីរ និងសហគមន៍ការពារស្មៅសមុទ្រមួយ ដែលមានទីតាំងស្ថិតនៅក្នុងដែនសហគមន៍នេសាទ។ ភូមិចង្ហោន ជាភូមិមួយរបស់ឃុំព្រែកស្នោត ប្រជាពលរដ្ឋនៅក្នុងភូមិនេះត្រូវបានចលនាឲ្យចូលរួមការពារ និងអភិរក្សធនធានសមុទ្រនៅក្នុងដែននេសាទ របស់ខ្លួនតាមរយៈការបង្កើតឲ្យមានសហគមន៍នេសាទ។ **សហគមន៍នេសាទនេះ** បានបង្កើតឡើងនៅឆ្នាំ2002 ក្រោមការ ជួយឧបត្ថម្ភ និងសំរបសំរួលខាងបច្ចេកទេស និងរដ្ឋបាលពីសំណាក់អង្គការUNEP និងរដ្ឋបាលជលផល។ សមាជិករបស់សហគមន៍មានចំនួនសរុបទាំងអស់ចំនួន412នាក់ ក្នុងនោះសមាជិកជាស្ត្រីចំនួន191នាក់ មានតួនាទីក្នុងការការពារធនធានសមុទ្រដូចជា ត្រី បង្គា ក្តាម ស្មៅសមុទ្រ...ក្នុងដែនសហគមន៍របស់ខ្លួនក្នុងទំហំ 1,521.18 ហិកតា ចំងាយ4គីឡូម៉ែត្រពីច្រាំង។ គោលបំណងការពារ និងអភិរក្សធនធានធម្មជាតិក្នុងសហគមន៍ គឺដើម្បីបង្កើនប្រាក់ចំណូល និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដោយសមស្របទៅតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

សហគមន៍ភូមិចង្ហោន ជាសហគមន៍ដែលមានទីតាំងស្ថិតនៅក្បែរទីតាំងបូមបង្កើតឃ្លងនាវាជាងគេ ដែលមានចំងាយប្រមាណជាង1គីឡូម៉ែត្រ។ ចំណែកឯទីតាំងរបស់សហគមន៍ពីរទៀត ដែលស្ថិតនៅក្នុងភូមិព្រែកស្នោត និងភូមិត្រពាំងរពៅមានចំងាយឆ្ងាយពីទីតាំងស្ពារឃ្លងនាវាប្រមាណពី4គីឡូម៉ែត្រ ទៅ6គីឡូម៉ែត្រ។ គោលបំណងនៃការបង្កើតជាសហគមន៍នេះ ក៏មិនខុសពីសហគមន៍ភូមិចង្ហោនដែរ គឺដើម្បីរក្សាការពារធនធានធម្មជាតិ បង្កើនប្រាក់ចំណូលកាត់បន្ថយភាពក្រីក្រ។ ដោយឡែកនៅឃុំបឹកទូក និងកោះតូច មិនមានវត្តមានសហគមន៍នោះទេ។ ផែនទីសហគមន៍នេសាទ និងសហគមន៍ការពារធម្មជាតិ មានបង្ហាញជូនក្នុងរូបភាព4.73។

តារាង 4.37 ផ្ទៃដីសហគមន៍តាមភូមិនីមួយៗរបស់ឃុំព្រែកស្នោត

ភូមិ	ផ្ទៃដីសហគមន៍ (ហិកតា)
ចង្ហោន	1,521.18
ព្រែកស្នោត	735.50
ព្រែកក្រែង និងត្រពាំងរពៅ	1,262.80
សរុប	3,519.48

<u>សូមបញ្ជាក់ថា ៖</u> ភូមិព្រែកក្រែង និងត្រពាំងរពៅមានដែនសហគមន៍រួមគ្នា

<u>☞សន្និដ្ឋានលើធនធានសេដ្ឋកិច្ច-សង្គម</u>

ក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានផ្នែកសេដ្ឋកិច្ច-សង្គមដែលមានស្រាប់នៅតំបន់គំរោង តាមទិន្នន័យគោល និងឯកសារនានាដែលមានស្រាប់ បានកំណត់យកឃុំគោលដៅចំនួន3ឃុំ ក្នុងនោះជ្រើសរើស9ភូមិមកសិក្សា ដើម្បីធ្វើការវាយតំលៃអំពីឥទ្ធិពលនៃគំរោងមកលើប្រជាពលរដ្ឋដែលនៅក្បែរតំបន់គំរោង។ តាមរយៈលទ្ធផលនៃការចុះសិក្សាផ្ទាល់របស់ក្រុមសិក្សា អាចធ្វើសន្និដ្ឋានបានថា៖

-ការតាំងលំនៅដ្ឋានរបស់ពួកគាត់ភាគច្រើនស្ថិតនៅក្បែរឆ្នេរ ហើយស្របតាមបណ្តោយឆ្នេរ។

-មុខរបរកសិប្រជាពលរដ្ឋតំបន់នេះរួមមានជាអ្នកនេសាទ អ្នកធ្វើស្រែចំការ មន្ត្រីរាជការ កម្មករ អ្នកលក់ដូរ អ្នកជាំដំណាំសមុទ្រ(សារាយ) ប៉ុន្តែភាគច្រើនជាអ្នកនេសាទ ឯកចំណែកមុខរបរធ្វើស្រែចំការគឺធ្វើតែរដូវវស្សាតែប៉ុណ្ណោះ។ ការនេសាទប្រជាពលរដ្ឋនៅតំបន់នេះធ្វើឡើងទាំងរដូវប្រាំង និងរដូវវស្សា ទោះបីនៅរដូវវស្សាមានការជាប់រវល់ធ្វើស្រែចំការយ៉ាងណាក៏ដោយ។ ជាទូទៅអ្នកចេញទៅនេសាទតិចជាង20ថ្ងៃមានភាគរយច្រើនជាងអ្នកចេញនេសាទប្រចាំថ្ងៃ។

-ចំណូលជាមធ្យមប្រចាំឆ្នាំ ជាទូទៅក្នុងមួយគ្រួសារប្រមាណ4,090ដុល្លាសហរដ្ឋអាមេរិក ឯការចំណាយទៅវិញប្រមាណ3,416ដុល្លាសហរដ្ឋអាមេរិក។

-ការប្រើប្រាស់ធនធានទឹករបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោង ជាទូទៅប្រើប្រាស់ទឹកអណ្តូង និងទឹកភ្លៀងដែលស្តុកទុក ព្រោះតំបន់នេះពុំទាន់មានបណ្តាញទឹកស្អាត។ ឯចំនែកថាមពលចំអិនអាហារវិញ ភាគច្រើនប្រើឧសដុតដែលពួកគាត់ទៅរកឧសងាប់ៗ តាមចង្កេះភ្នំបូកគោ និងព្រៃកោងកាង ។ ចំពោះបណ្តាញអគ្គិសនីសំរាប់ប្រើប្រាស់ គឺនៅមានកម្រិតព្រោះភូមិភាគច្រើនក្នុងឃុំទាំងបីខ្លះពុំទាន់មានបណ្តាញអគ្គីសនីចូលមកដល់។

-ក្នុងវិស័យអប់រំនៅឃុំទាំងបីឃើញថាអត្រាអ្នកចូលរៀនមានចំនួនច្រើនធៀបនឹងអនក្ខរជន ម្យ៉ាងទៀតយើងសង្កេតឃើញមានសាលាសាលារៀនបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។

-ចំពោះវិស័យសុខភាពសាធារណៈគឺនៅមានកម្រិត ទោះបីជាតាមឃុំនីមួយៗមានមណ្ឌលសុខភាពក៏ដោយ ពេលមានជំងឺធ្ងន់ម្តងៗគឺបញ្ជូនមកមន្ទីរពេទ្យបង្អែកខេត្តកំពត។

-ចំពោះបញ្ហាអនាម័យ ពិសេសសំរាមគឺពុំទាន់មានសេវាកម្មប្រមូលសំរាមទេ ភាគច្រើនការទុកដាក់សំរាមពុំមានសណ្តាប់ធ្នាប់ល្អ។ រីឯបង្គន់អនាម័យភាគច្រើនពុំទាន់មានគឺបន្ទោរបង់ពាស់វាលពាស់កាលប៉ះពាល់ដល់ប្រភពទឹក។

-ក្បែរតំបន់គំរោងមានតំបន់រមណីយដ្ឋានមួយកន្លែងឈ្មោះ Nataya Round House Coral Resort ស្ថិតនៅភូមិព្រែកអំពិល និងសហគមន៍ចំនួន3 គឺសហគមន៍នេសាទពីរ និងសហគមន៍ការពារស្មៅសមុទ្រមួយ ដែលមានទីតាំងស្ថិតនៅក្នុងដែនសហគមន៍នេសាទ។